**ស្ថានទូតអូស្ត្រាលី**

**រាជធានីភ្នំពេញ**


# សេចក្តីប្រកាសព័ត៌មាន

# អូស្ត្រាលីគាំទ្រកម្ពុជា

# ក្នុងការកាត់បន្ថយភាពក្រីក្រតាមរយៈការស្រាវជ្រាវកសិកម្ម

វេទិកាស្រាវជ្រាវអំពីស្រូវអង្ករនៅកម្ពុជាបានបើកនៅថ្ងៃនេះ (ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១២) ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។ វេទិកានេះគឺជាលទ្ធផលនៃភាពជាដៃគូប្រកបដោយផ្លែផ្ការវាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់និង នេសាទ វិទ្យាស្ថានអន្តរជាតិស្រាវជ្រាវដំណាំស្រូវ និង រដ្ឋាភិបាលអូស្ត្រាលី ដែលជាផ្នែកមួយនៃគំរោងកម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា (CAVAC)។

វេទិកានេះបានអញ្ជើញតំណាងមកពីរាជរដ្ឋាភិបាលកម្ពុជា ស្ថាប័នស្រាវជ្រាវ វិស័យឯកជន និង ដៃគូអភិវឌ្ឍន៍ ដើម្បីពិចារណាថាតើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីពង្រឹងបន្ថែមទៀតនូវផលិតកម្មស្រូវនៅកម្ពុជា។ នៅក្នុងវេទិកានេះលទ្ធផលនៃការស្រាវជ្រាវបច្ចុប្បន្ននឹងត្រូវបាន ពិភាក្សាជាមួយនឹងបញ្ហាប្រឈមនានាដែលផលិតកម្មស្រូវនៅកម្ពុជាកំពុងជួបប្រទះ ដើម្បីកំណត់អាទិភាពការស្រាវជ្រាវនាពេលអនាគត។

ថ្លែងសុន្ទរកថានៅក្នុងឱកាសបើកវេទិកាស្រាវជ្រាវដំណាំស្រូវ លោកជំទាវ **ផេននី រីឆាដស៍** ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជាបានប្រកាសថា "អូស្ត្រាលីនឹងចូលរួមវិភាគទានចំនួន១លានដុល្លារអូស្ត្រាលីដល់ជំរឿនកសិកម្មលើកទីមួយនៅកម្ពុជា។ ជំរឿននេះនឹងផ្តល់នូវទិន្នន័យដ៏មានសារៈសំខាន់ដល់វិស័យកសិកម្មដែលនឹងត្រូវប្រើប្រាស់ដើម្បីកែលំអគោលនយោបាយ និង គំរោងកម្មវិធីដែលដោះស្រាយតម្រូវការរបស់ប្រជាកសិករ កម្ពុជា និង កាត់បន្ថយភាពក្រីក្រ។ ទិន្នន័យនេះនឹងប្រើប្រាស់សម្រាប់កំណត់បែងចែកធនធានជាតិនិងអន្តរជាតិឲ្យបានចំទិសដៅសម្រាប់វិស័យកសិកម្ម និង អភិវឌ្ឍន៍ជនបទ រួមបញ្ចូលទាំងគោលនយោបាយនាំចេញអង្កររបស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ"។


No. 16B National Assembly Street, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, Kingdom of Cambodia
Telephone: 855 23 213 470 Facsimile: 855 23 213 413

អូស្ត្រាលីបាននិងកំពុងជួយប្រជាកសិករកម្ពុជាអស់រយៈពេល២៥ឆ្នាំមកហើយ ហើយជំនួយនេះបានរួមចំណែកធ្វើឲ្យទិន្នផលស្រូវកើនឡើងជាងទ្វេដងនៅក្នុងរយៈពេលនេះ។ ជាលទ្ធផល ការគាំទ្រនេះបានជួយកែលំអសុវត្ថិភាពស្បៀងសម្រាប់ប្រជាជនកម្ពុជា និង បង្កើនប្រាក់ចំណូលដល់កសិករកម្ពុជា។

នាពេលថ្មីៗនេះ វិស័យកសិកម្មកម្ពុជាដែលមានសន្ទុះខ្លាំងក្លា និង ភាពស្មុគស្មាញជាងមុនបានលេចឡើងរួមជាមួយនឹងទីផ្សារសម្រាប់សម្ភារៈកសិកម្មដូចជា ពូជនិងជី ព្រមទាំងកាលានុវត្តភាពសម្រាប់ការកែច្នៃ និង ការនាំចេញ។ អូស្ត្រាលីកំពុងជួយគាំទ្រកម្ពុជាដើម្បីទាញប្រយោជន៍ឲ្យបានច្រើនបំផុតពីកាលានុវត្តភាពទាំងនោះ។

កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា (CAVAC) ដែលមានថវិកា៥៣លានដុល្លារអូស្ត្រាលី ជាកម្មវិធីកសិកម្មដ៏សំខាន់មួយរបស់អូស្ត្រាលី កំពុងធ្វើការជាដៃគូជាមួយវិស័យសាធារណៈ និង វិស័យឯកជន ដើម្បីជួយបង្កើនប្រាក់ចំណូលដល់កសិករខ្នាតតូចប្រមាណ ២៣ម៉ឺនគ្រួសារនៅឆ្នាំ២០១៦។ កម្មវិធីនេះនឹងជួយគាំទ្ររាជរដ្ឋាភិបាលកម្ពុជាឆ្ពោះទៅកាន់គោលដៅក្នុងការនាំចេញអង្ករ១លានតោនក្នុងមួយឆ្នាំ នៅឆ្នាំ២០១៥។

*សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖*
*លោក **ដេវ ហ្គ័រដ្យ** (Dave Gordge) អ្នកនាំពាក្យប្រចាំស្ថានទូតអូស្ត្រាលី*
*ទូរស័ព្ទលេខ ០២៣ ២១៣ ៤៧០ លេខបន្ត ៥០២*

ស្ថានទូតអូស្ត្រាលី រាជធានីភ្នំពេញ
ថ្ងៃទី ៣០ មេសា ២០១២